CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 18 ខែមិថុនា ឆ្នាំ 2021
ទំនាក់ទំនង ៖ ឡារ៉ា ធឺនប៊ុល (Lara Turnbull) អ្នកគ្រប់គ្រង ស្តីទី នៃការិយាល័យសុខភាពសហគមន៍ របស់នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស ឡុងប៊ិច, 562.570.4294, ឡារ៉ា (Lara) ។
Turnbull@longbeach.gov ។

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# ឡុងប៊ិចលើកទឹកចិត្ត អ្នកបើកបរ ឱ្យដកឃ្លា ពីការប្រើប្រាស់ ទូរសព្ទ មួយរយៈពេល ។

ដោយចូលជាធរមាន នៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2021, អ្នកបើកបរ នៅកាលីហ្វ័រញ៉ា អាចប្រឈមនឹង ទោសទណ្ឌ កាន់តែច្រើនឡើង សម្រាប់ការប្រើប្រាស់ ឧបករណ៍ចល័តកាន់នឹងដៃ ខណៈពេលបើកបរយានយន្ត ហើយនាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស (នាយកដ្ឋានសុខាភិបាល) លើកទឹកចិត្ត អ្នកបើកបរ ឱ្យដកឃ្លា ពីការប្រើប្រាស់ទូរសព្ទ និងសម្លឹងផ្តោតលើដងផ្លូវ ។ ច្បាប់ថ្មីនេះ បង្កើនកម្រិតទោសទណ្ឌ ចំពោះបទល្មើសបើកបរ ដោយមានការរំខាន ដើម្បីរួមបញ្ចូល ពិន្ទុ ដាក់នៅក្នុង កំណត់ត្រា របស់អ្នកបើកបរ ។ នាពេលបច្ចុប្បន្ននេះ ទោសទណ្ឌ តែមួយគត់ ចំពោះការប្រើប្រាស់ទូរសព្ទចល័ត នៅនឹងដៃនោះ គឺប្រាក់ពិន័យ ចំនួន 162 ដុល្លារ ។

ក្រោមច្បាប់បច្ចុប្បន្ននេះ អ្នកបើកបរមិនត្រូវបានអនុញ្ញាត ឱ្យកាន់ទូរសព្ទ ឬឧបករណ៍ អេឡិចត្រូនិកផ្សេងៗ ទៀត ខណៈពេលកំពុងកាន់ចង្កូតបើកបរ នោះទេ ។ អ្នកបើកបរដែលមានអាយុ ក្រោម 18 ឆ្នាំ មិនត្រូវបានអនុញ្ញាត ឱ្យប្រើប្រាស់ទូរសព្ទ រួមទាំង ករណីប្រើប្រាស់ ដោយមិនចាប់កាន់នឹងដៃ ដោយសារហេតុផលណាមួយ នោះទេ ។  ច្បាប់ថ្មីរបស់កាលីហ្វ័រញ៉ា កំណត់ថា អ្នកបើកបរ ដែលរងការផ្តន្ទាទោស ពីបទល្មើសបើកបរ ដោយមានការរំខាន អាចទទួលបាន មួយពិន្ទុ ដាក់ទៅក្នុង កំណត់ត្រារបស់ពួកគេ សម្រាប់ការផ្តន្ទាទោស ម្តង ក្នុងរយៈពេល 36 ខែ បន្ទាប់ពីមានការផ្តន្ទាទោសលើកមុន ចំពោះបទល្មើសដូចគ្នានេះ ។

ទោះបីជាអ្នកបើកបរ បានចាប់ផ្តើមប្រើប្រាស់ទូរសព្ទដៃ របស់ពួកគេ ក្នុងចំនួនតិចជាង ខណៈពេលកំពុងបើកបរ នៅពេលការប្រើប្រាស់ទូរសព្ទ ដោយគ្មានការចាប់កាន់នឹងដៃ បានក្លាយទៅជាច្បាប់ក្តី, ក៏ការបើកបរ ដោយមានការរំខាន នៅតែជាបញ្ហាសុវត្ថិភាព ធ្ងន់ធ្ងរ នៅឡុងប៊ិច ដែរ ។ នៅដើមឆ្នាំនេះ ក្នុងគម្រោងមួយ ដែលមានមូលនិធិគាំទ្រ ពីការិយាល័យសុវត្ថិភាពចរាចរណ៍ កាលីហ្វ័រញ៉ា, នាយកដ្ឋានសុខាភិបាល រៀបចំកម្មវិធីមើលផ្លូវ ឡុងប៊ិច (RoadwatchLB) ប្រចាំឆ្នាំ ជាលើកដំបូង ។ អ្នកស្ម័គ្រចិត្តសហគមន៍ និងនិយោជិតសាលាក្រុង ត្រូវបានដាក់ពង្រាយ នៅតាមចំណុចផ្លូវប្រសព្វ នៅទូទាំងឡុងប៊ិច ដើម្បីសង្កេតមើល និងប្រមូលទិន្នន័យ អំពីការបើកបរ ដោយមានការរំខាន ។ ក្នុងរយៈពេល 30 ម៉ោង នៃអំឡុងពេល បីថ្ងៃ, អ្នកស្ម័គ្រចិត្តបានសង្កេតឃើញ មានអ្នកបើកបរ ជិត 1 000 នាក់ ប្រើប្រាស់ឧបករណ៍កាន់នឹងដៃ ។

ក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យផ្លូវមានសុវត្ថិភាព ប្រសើរឡើង, នាយកដ្ឋានសុខាភិបាល បន្តរៀបចំ សិក្ខាសាលាអប់រំ សម្រាប់យុវជន និងមនុស្សធំ វ័យក្មេង ដើម្បីលើកកម្ពស់ ការបើកបរ ប្រកបដោយ

# PRESS RELEASE

សុវត្ថិភាព និងគ្មានការរំខាន ហើយប្រមូលទិន្នន័យមូលដ្ឋាន ពាក់ព័ន្ធនឹង ការបើកបរ ដោយមានការរំខាន និងធ្វើការវាយតម្លៃ លើទិន្នន័យទាំងនោះ ដើម្បីផ្តល់ជាព័ត៌មាន ដល់កិច្ចខិតខំប្រឹងប្រែង របស់កម្មវិធីនានានៅពេលអនាគត ។ ដោយសហការ ជាមួយនាយកដ្ឋានផ្សេងៗ ទៀត របស់សាលាក្រុង និងដៃគូសហគមន៍, នាយកដ្ឋានសុខាភិបាល នឹងរៀបចំកម្មវិធី សប្តាហ៍លើកកម្ពស់ ការយល់ដឹង អំពីសុវត្ថិភាព នៅតាមដងផ្លូវ នៅខែសីហា និង សប្តាហ៍សុវត្ថិភាពអ្នកបើកបរ ជាក្មេងជំទង់ នៅខែតុលា ខណៈដែលផ្តល់ការគាំទ្រ ដល់កិច្ចខិតខំប្រឹងប្រែងនានា នៅទូទាំងទីក្រុង ដែលមានគោលដៅលុបបំបាត់ មរណភាព និង របួសធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងចរាចរណ៍ នៅឡុងប៊ិចផងដែរ ។

អ្វីមួយ ដែលធ្វើឱ្យលោកអ្នក លែងសម្លឹងមើលដងផ្លូវ ឬ លែងកាន់ដៃចង្កូត ត្រូវបានចាត់ជា ការរំខាន ។ ដើម្បីរក្សាដងផ្លូវ ឱ្យមានសុវត្ថិភាព ប្រសើរឡើង សម្រាប់អ្នកគ្រប់គ្នា, នាយកដ្ឋានសុខាភិបាល ណែនាំឱ្យអ្នកបើកបរ ឈប់អែបខាង ដើម្បីទូរសព្ទ ឬផ្ញើសារ ។ អ្នកបើកបរក៏គួរ បិទសម្លេងទូរសព្ទរបស់ពួកគេ, ប្រើមុខងារ កុំរំខាន, ឬដាក់ទូរសព្ទ ឱ្យនៅផុតពីដៃ មុនពេលចូលកាន់ដៃចង្កូត ។

សំណួរពីប្រព័ន្ធផ្សព្វផ្សាយ អាចបញ្ជូនទៅ ឡារ៉ា ធឺនប៊ុល (Lara Turnbull) អ្នកគ្រប់គ្រង ស្តីទី នៃការិយាល័យសុខភាពសហគមន៍ របស់ក្រសួងសុខាភិបាល និងសេវាមនុស្ស ឡុងប៊ិច តាមរយៈ 562.570.4294, Lara.Turnbull@longbeach.gov ។

# # #